00574239

E144.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 26 / 07 / 2010
ម៉ោង (Time/Heure): 15:55
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០១/១៨ កក្កដា ២០០៧/អវតក/អជសង
**Case File/Dossier No. 001/18-07-2007/ECCC/TC**

| | |
|---|---|
| ចំពោះមុខ | ចៅក្រម និល ណុន ជាប្រធាន |
| | ចៅក្រម Silvia CARTWRIGHT |
| | ចៅក្រម យ៉ា សុខន |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម ធូ មណី |
| ក្រឡាបញ្ជីសវនាការ | លឹម ស៊ុយហុង, Matteo CRIPPA, សែ កុលវុឌ្ឍី<br>Natacha WEXELS-RISER , ឌុច ផារី |
| កាលបរិច្ឆេទសវនាការ | ចាប់ផ្តើមថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ និងបញ្ចប់កិច្ចពិភាក្សាដេញដោល ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ |
| កាលបរិច្ឆេទប្រកាសសាលក្រម | ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ |
| ចំណាត់ថ្នាក់ឯកសារ | សាធារណៈ |

## មតិជំទាស់របស់ចៅក្រម Jean-Marc LAVERGNE ពាក់ព័ន្ធទៅនឹងការកំណត់ទោស

**<u>សហព្រះរាជអាជ្ញា</u>**

ជាលាង
Andrew CAYLEY

**<u>ជនជាប់ចោទ</u>**

កាំង ហ្កេកអ៊ាវ ហៅ ឌុច

**<u>មេធាវីជនជាប់ចោទ</u>**

ការ សាវុត្ថ
François ROUX
Marie-Paule CANIZARÈS

ឯកសារបានចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 26 / 07 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

00574240

សំណុំរឿងលេខៈ ០០១/១៨ កក្កដា ២០០៧/អវតក/អជសង
E188.1

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
គង់ ពិសី
ហុង គឹមសួន
យុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANONNE

ទី ស្រ៊ីនណា
Pierre Olivier SUR
Alain WERNER
Brianne McGONIGLE
Annie DELAHAIE
Elizabeth RABESANDRATANA
Karim KHAN
Fabienne TRUSSES-NAPROUS
Christine MARTINEAU

១. ខ្ញុំមានការសោកស្តាយដែលត្រូវបញ្ចេញមតិជំទាស់ទៅនឹងសេចក្តីសម្រេច តាមមតិភាគច្រើនរបស់អង្គជំនុំជម្រះ ត្រង់ផ្នែកដែលពាក់ព័ន្ធទៅនឹងការកំណត់ទោសដែលត្រូវផ្តន្ទាលើជនជាប់ចោទ កាំង ហ្គេកអ៊ាវ។ មតិជំទាស់របស់ខ្ញុំមិនមែនទាក់ទងទៅនឹងវិសាលភាពនៃពិរុទ្ធភាពរបស់ជនជាប់ចោទ ការវាយតម្លៃអំពីប្រភេទធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម ហើយក៏មិនមែនទាក់ទងទៅនឹងស្ថានទម្ងន់ទោស ឬស្ថានសម្រាលទោស ដែលត្រូវអនុវត្តទៅលើជនជាប់ចោទនោះឡើយ។ ម្យ៉ាងទៀត អង្គជំនុំជម្រះបានសម្រេចដោយសំឡេងឯកច្ឆន្ទរួចមកហើយថា ជនជាប់ចោទ នឹងមិនត្រូវបានផ្តន្ទាទោសអតិបរមានៃទោសចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលខ្លួនបានប្រព្រឹត្ត ពោលគឺទោសជាប់ពន្ធនាគារអស់មួយជីវិតនោះទេ។ ផ្ទុយទៅវិញ ជនជាប់ចោទត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគារក្នុងរយៈពេលកំណត់មួយច្បាស់លាស់។

២. អ្វីដែលខ្ញុំមានការយល់ឃើញផ្ទុយពីសហការីទាំងឡាយរបស់ខ្ញុំ គឺស្ថិតនៅក្នុងដំណាក់កាលនៃការផ្តល់សំអាងហេតុរបស់អង្គជំនុំជម្រះ ហើយពាក់ព័ន្ធទៅនឹងការវិភាគអំពីក្របខណ្ឌគតិយុត្តសមស្របដែលអង្គជំនុំជម្រះត្រូវប្រកាន់យកក្នុងការកំណត់ទោស។ ទោះបីជាគ្មានអ្វីដែលត្រូវសង្ស័យទេថា តាមវិធាន៩៨(៥) នៃវិធានផ្ទៃក្នុង ការប្រកាសទោសត្រូវធ្វើឱ្យស្របទៅនឹងកិច្ចព្រមព្រៀង ច្បាប់អ.វ.ត.ក និងវិធានផ្ទៃក្នុង ក៏ដោយ ក៏អង្គជំនុំជម្រះបានកត់សម្គាល់រួចហើយថា លិខិតូបករណ៍ទាំងនេះ មិនបានចែងពីគោលការណ៍ និងកត្តានានាដែលត្រូវយកមកពិចារណានៅដំណាក់កាលនៃការកំណត់ទោសនោះទេ។ ជាពិសេស លិខិតូបករណ៍ទាំងនេះមិនបានបញ្ជាក់ផងទេថា វិធានដែលត្រូវអនុវត្តទៅលើករណីនេះ ត្រូវអនុលោមតាមនីតិអន្តរជាតិ តាមនីតិជាតិ ឬតាមការបូកបញ្ចូលគ្នានៃនីតិទាំងពីរនេះ[១]។ ដើម្បីធ្វើការសម្រេចយកក្របខណ្ឌគតិយុត្តមួយសមស្រប អង្គជំនុំជម្រះបានធ្វើការបកស្រាយភាពស្ងៀមស្ងាត់នេះ តាមរយៈការពិនិត្យទៅលើបទដ្ឋានសមស្របទាំងឡាយដែលពាក់ព័ន្ធទៅនឹងបញ្ហានេះ ទាំងនៅក្នុងនីតិអន្តរជាតិជាធរមាន និងទាំងនៅក្នុងបទដ្ឋាននៃនីតិកម្ពុជា។ ក៏ប៉ុន្តែសម្រាប់រូបខ្ញុំ ទាំងការពិនិត្យលើច្បាប់ ទាំងគោលការណ៍នៃការបកស្រាយច្បាប់ មិនអាចអនុញ្ញាតឱ្យអង្គជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទដាក់ពន្ធនាគារលើសពី៣០ឆ្នាំបានទេ ប្រសិនបើអង្គជំនុំជម្រះមិនសម្រេចផ្តន្ទាទោសអតិបរមាដាក់ពន្ធនាគារអស់មួយជីវិតនោះ។

៣. នៅក្នុងការពិនិត្យមើលលើបទដ្ឋានពាក់ព័ន្ធនៃនីតិអន្តរជាតិ អង្គជំនុំជម្រះបានកត់សម្គាល់ឃើញថា ទោះបីជាយុត្តិសាស្ត្រនៃតុលាការ *មិនអចិន្ត្រៃយ៍* បានផ្តល់ដល់ចៅក្រមនូវអំណាចឆន្ទានុសិទ្ធិក្នុងការសម្រេចអំពីការ

---

[១] សូមមើល ផ្នែក ៣.២.១ (កថាខណ្ឌ ៥៧៥)។

កំណត់ទោសក៏ពិតមែន ក៏ប៉ុន្តែមាត្រា៧៧(១) នៃលក្ខន្តិកៈទីក្រុងរ៉ូម បានបញ្ញត្តិយ៉ាងច្បាស់លាស់ពាក់ព័ន្ធនឹងចំណុចនេះ ដោយហេតុថាមាត្រានេះមិនបានចែងអំពីការកំណត់ទោសដែលស្ថិតនៅចន្លោះរវាងទោសជាប់ពន្ធនាគារអស់មួយជីវិត និងទោសជាប់ពន្ធនាគាររយៈពេល៣០ឆ្នាំនោះទេ។ ហេតុដូច្នេះ យើងអាចសន្និដ្ឋានបានថា នៅក្នុងនីតិអន្តរជាតិគឺមានគោលការណ៍រួមតែមួយដែលពាក់ព័ន្ធទៅនឹងការកំណត់ទោស[២]។

៤. ចំពោះការពិនិត្យលើច្បាប់ជាតិវិញ ជាពិសេសលើបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌថ្មីនៃព្រះរាជាណាចក្រកម្ពុជា[៣] ក្រមនេះបានចែងយ៉ាងច្បាស់លាស់ពាក់ព័ន្ធនឹងបញ្ហានេះ ជាក់ស្តែងមាត្រា៩៥ បានចែងថា កាលណាការផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតមិនត្រូវបានអនុវត្ត ដោយសារតែស្ថានសម្រាលនានានោះ អតិបរមានៃទោសដែលត្រូវផ្តន្ទាមិនត្រូវលើសពី៣០ឆ្នាំឡើយ[៤]។

៥. ខ្ញុំយល់ឃើញថា ការយោងទៅលើច្បាប់ជាតិជាការយោងមួយដែលមានលក្ខណៈសមហេតុសមផលបំផុត ដោយហេតុថា អ.វ.ត.ក. ជាតុលាការមួយដែលមានលក្ខណៈពិសេស ហើយលើសពីនេះ តុលាការកូនកាត់មួយនេះមានសមត្ថកិច្ចជំនុំជម្រះទៅលើឧក្រិដ្ឋកម្មទាំងឡាយ ទាំងឧក្រិដ្ឋកម្មអន្តរជាតិ និងឧក្រិដ្ឋកម្មជាតិ និងដោយហេតុថា ឯកសារគ្រឹះនានា មិនបានធ្វើការបែងចែកអំពីរបបនៃទោសសម្រាប់អនុវត្តទៅលើបទល្មើសទាំងពីរប្រភេទនេះទេ។ ដូច្នេះ ទោះបីជារបបនៃទោសនេះ អាចត្រូវបានចាត់ទុកថាមានលក្ខណៈពិសេស (*sui generis*) ក៏ដោយ ក៏វាមានការលំបាកក្នុងការកាត់ផ្តាច់របបនេះចេញទាំងស្រុងពីនីតិជាតិដែរ។

៦. ម្យ៉ាងវិញទៀត ការយោងទៅលើបទប្បញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន ពោលគឺក្រមព្រហ្មទណ្ឌថ្មី ជាការយោងមួយដែលមានលក្ខណៈសមហេតុសមផលផងដែរ។ នេះជាការបញ្ជាក់ឲ្យឃើញថា អ្នកតាក់តែងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា បានចាត់ទុកបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌថ្មីរបស់ខ្លួន ថាជាបទប្បញ្ញត្តិដែលឈានមុខគេក្នុងវិស័យយុត្តិធម៌ និងច្បាប់ ហើយចំណែកមាត្រា៩៥ នៃក្រមនេះ គឺជាផ្នែកមួយនៃ

---

[២] សូមមើល ផ្នែក ៣.២.១ (កថាខណ្ឌ ៥៧៦, ៥៩១-៥៩៣)។

[៣] ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿងជាភាសាខ្មែរ កាលពីថ្ងៃទី០៥ ខែមករា ឆ្នាំ២០១០ និងជាភាសា អង់គ្លេស និងបារាំង កាលពីថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០ (ឯកសារលេខ E180)។ បើទោះបីជាដីកាចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១០ បានអនុញ្ញាតឲ្យភាគីធ្វើសេចក្តីសន្និដ្ឋានពាក់ព័ន្ធទៅនឹងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងគន្ថីទី១ នៃក្រមនេះ (ឯកសារលេខ E180/1) ក៏ដោយ ក៏មិនមានភាគីណាមួយបានដាក់សេចក្តីសន្និដ្ឋានរបស់ខ្លួនដែរ។ ផ្ទុយទៅវិញ មេធាវីការពារក្តីបានលើកឡើងអំពីបញ្ហានៃការអនុវត្តបទប្បញ្ញត្តិទាំងនេះ (សូមពិនិត្យមើលប្រតិចារឹក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ (មេធាវីការពារក្តី) ទំព័រ ៥១)។

[៤] មាត្រា៩៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ បានចែងថា "កាលណាបទល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ចៅក្រមដែលផ្តល់ស្ថានសម្រាលទោស អាចប្រកាសទោសដាក់ពន្ធនាគារក្នុងចន្លោះរវាង១៥ឆ្នាំ (ដប់ប្រាំឆ្នាំ) និង៣០ឆ្នាំ (សាមសិប ឆ្នាំ)"។

បទប្បញ្ញត្តិទូទៅដែលមានអនុភាពអនុវត្តភ្លាមៗតែម្តង នៅក្នុងប្រព័ន្ធតុលាការកម្ពុជា[៥]។ ម្យ៉ាងវិញទៀត ក្រៅតែពីបញ្ហានៃការអនុវត្តភ្លាមៗនៃច្បាប់ព្រហ្មទណ្ឌជាតិដែលមានលក្ខណៈស្រាលជាងនោះ ទោះបីជាការអនុវត្តដោយផ្ទាល់នៃច្បាប់ជាតិចំពោះរឿងក្តីដែលត្រូវបានចាត់ទុកថាស្ថិតនៅក្រោមច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដូចជារឿងក្តីនេះក៏ដោយ ក៏យើងសង្កេតឃើញថា មិនមានអំណះអំណាងស្របច្បាប់ណាមួយដែលអាចឱ្យយើងសន្និដ្ឋានបានថា បទប្បញ្ញត្តិទោសដែលត្រឹមត្រូវសម្រាប់អនុវត្តក្នុងប្រព័ន្ធតុលាការនៃព្រះរាជាណាចក្រកម្ពុជាគឺមិនអាចយកមកអនុវត្តនៅចំពោះមុខ អ.វ.ត.ក បាននោះឡើយ។

៧. ម្យ៉ាងទៀត គួរកត់សម្គាល់ផងដែរថា គោលការណ៍ទាំងឡាយដែលប្រកាន់យកដោយអង្គជំនុំជម្រះ ចំពោះការបដិសេធនូវការអនុវត្តអតិបរមានៃទោស គឺមានលក្ខណៈស្របគ្នាទៅនឹងបទប្បញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ពាក់ព័ន្ធនឹងគោលការណ៍ឯកត្តកម្មនៃទោស ក៏ដូចជាស្ថានសម្រាលទោស[៦]។

៨. ជាចុងក្រោយ យោងតាមគោលការណ៍នៃការបកស្រាយច្បាប់ ជាពិសេសនៅពេលដែលច្បាប់នេះមិនមានភាពច្បាស់លាស់ ឬមិនមានចែង ពេលនោះគេត្រូវប្រកាន់យកនូវដំណោះស្រាយដែលផ្តល់នូវប្រយោជន៍ដល់ជនជាប់ចោទ នៅពេលមានភាពមិនច្បាស់លាស់ក្នុងការអនុវត្តវិធានជាក់លាក់ណាមួយនោះ។ ជាការពិត ក្រៅពីគោលការណ៍ដែលគេទទួលស្គាល់ជាទូទៅដែលបានចែងថា វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទនោះ[៧] វិធាន២១(១) នៃវិធានផ្ទៃក្នុង ក៏បានចែងផងដែរថា ច្បាប់ អ.វ.ត.ក. និងវិធានផ្ទៃក្នុងត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនជាប់ចោទ[៨]។

---

[៥] សូមមើលព្រះរាជក្រម ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៦, ឯកសារលេខ E180.1។ ម្យ៉ាងវិញទៀត ប្រការដែលគន្ថីទីពីរនៃក្រមព្រហ្មទណ្ឌដែលចែងអំពីនិយមន័យបទល្មើសដែលអាចដាក់ទណ្ឌកម្មបាន រួមទាំងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម នឹងចូលជាធរមាននៅខែធ្នូ ឆ្នាំ២០១០ មិនមានផលប៉ះពាល់អ្វីនោះទេ ដោយហេតុថា គោលការណ៍ដែលកំណត់នៅក្នុងគន្ថីទីមួយ គឺជាគោលការណ៍ទូទៅដែលអនុវត្តចំពោះគ្រប់បទឧក្រិដ្ឋថ្នាក់ជាតិទាំងអស់ និងម្យ៉ាងទៀត អ្នកតាក់តែងច្បាប់យល់ឃើញយ៉ាងច្បាស់ថា គោលការណ៍ទាំងនេះ ក៏អាចអនុវត្តផងដែរចំពោះបទឧក្រិដ្ឋដែលមានកម្រិតធ្ងន់ធ្ងរ យ៉ាងហោចណាស់ស្មើនឹងកម្រិតធ្ងន់ធ្ងរនៃបទឧក្រិដ្ឋទាំងឡាយដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់អង្គជំនុំជម្រះនេះដែរ ។

[៦] មាត្រា៩៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ចែងថា "កិរិយាមាយាទរបស់ជនល្មើសក្រោយពេលប្រព្រឹត្តបទល្មើស" ដែលអាចរាប់បញ្ចូលយ៉ាងច្បាស់ជាអាទិ៍ នូវការទទួលស្គាល់ទំនួលខុសត្រូវរបស់ខ្លួនចំពោះបទល្មើស ការបង្ហាញនូវវិប្បដិសារី និងការសហការណ៍ជាមួយតុលាការ សុទ្ធសឹងជាធាតុផ្សំដែលត្រូវយកមកពិចារណាក្នុងគោលការណ៍ឯកត្តកម្មនៃទោស។ ម្យ៉ាងវិញទៀត មាត្រា៩៣ នៃក្រមដដែលនេះ កំណត់និយមន័យស្ថានសម្រាលទោសជាលក្ខណៈទូលំទូលាយថា អាស្រ័យទៅនឹង "ប្រភេទបទល្មើស ឬ បុគ្គលិកលក្ខណៈនៃជនជាប់ចោទ"។

[៧] គោលការណ៍ដែលចែងថា វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ មិនអនុវត្តចំពោះតែការវាយតម្លៃអំពីធាតុផ្សំនៃភស្តុតាងពាក់ព័ន្ធនឹងពិរុទ្ធភាពរបស់ជនជាប់ចោទប៉ុណ្ណោះទេ ប៉ុន្តែមានអានុភាពកាន់តែទូលំទូលាយពាក់ព័ន្ធនឹងការបកស្រាយលិខិត

៩. ក្នុងន័យនេះ វាមិនមែនជាបញ្ហាថា តើការអនុវត្តក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ បានរំលោភបំពានបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង អ.វ.ត.ក. ដែរ ឬយ៉ាងណានោះទេ ប៉ុន្តែគេគ្រាន់តែធ្វើការស្វែងយល់ថា តើគេត្រូវបកស្រាយគោលការណ៍ទាំងឡាយដែលមិនមានចែងក្នុងកិច្ចព្រមព្រៀង ឬមិនមានចែងនៅក្នុងច្បាប់ អ.វ.ត.ក. តាមវិធីណាតែប៉ុណ្ណោះ។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន សហការីរបស់ខ្ញុំ បានជ្រើសរើសយកបទដ្ឋានមួយដែលពុំមែនជាបទដ្ឋានរួមរបស់នីតិព្រហ្មទណ្ឌអន្តរជាតិ ហើយក៏មិនមែនជាផ្នែកមួយនៃបទដ្ឋានច្បាប់កម្ពុជាដែលថ្មីបំផុតដែរ ប៉ុន្តែវាជាបទដ្ឋានដែលផ្តល់ជាប្រយោជន៍តិចតួចបំផុតដល់ជនជាប់ចោទទៅវិញ។ ខ្ញុំយល់ឃើញថាការយកបទដ្ឋាននេះមកអនុវត្តគឺមិនស្របគ្នានឹងគោលការណ៍នៃការបកស្រាយច្បាប់ទេ ដូច្នេះ ខ្ញុំយល់ឃើញក្នុងករណីនេះថា ច្បាប់មិនអនុញ្ញាតឲ្យអង្គជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទ កាំង ហ្កេកអ៊ាវ ដាក់ពន្ធនាគារលើសពី៣០ឆ្នាំបានឡើយ។

[ហត្ថលេខា]

Jean-Marc LAVERGNE

---

បទដ្ឋានគតិយុត្តដែលត្រូវអនុវត្ត នៅពេលដែលលិខិតបទដ្ឋានទាំងនោះមានលក្ខណៈស្រពេចស្រពិល ឬមិនច្បាស់លាស់។ ឧទាហរណ៍ សូមមើលមាត្រា២២(២) នៃលក្ខន្តិកៈទីក្រុងរ៉ូម និងមាត្រា៣(ខ) នៃវិធាននីតិវិធី និងភស្តុតាងរបស់តុលាការពិសេសសម្រាប់ប្រទេសលីបង់។ ឧទាហរណ៍ ក្នុងករណីមានភាពមិនច្បាស់លាស់កើតចេញពីភាពផ្ទុយគ្នារវាងអត្ថបទជាភាសាបារាំង និងអត្ថបទជាភាសាអង់គ្លេសនៃលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ូវ៉ាន់ដា សូមមើល៖ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Clément Kayishema នឹង Obed Ruzindana* សំណុំរឿងលេខ ICTR-95-1-A សាលដីការបស់អង្គជំនុំជម្រះ តុលាការកំពូល ICTR ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌទី១៥១ ឬក្នុងករណីមានភាពមិនច្បាស់លាស់ពាក់ព័ន្ធជាទូទៅនឹងការកំណត់និយមន័យបទឧក្រិដ្ឋ សូមមើល៖ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Radislav Krstić* សំណុំរឿងលេខ IT-98-33-T សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY ថ្ងៃទី០២ ខែសីហា ឆ្នាំ២០០១ កថាខណ្ឌ ៤៩១-៥០៣។

[៨] គោលការណ៍ដែលបានលើកឡើងនេះ មិនត្រូវបានកំណត់តែចំពោះការបកស្រាយនិយមន័យនៃអំពើដែលជាធាតុផ្សំនៃបទល្មើសប៉ុណ្ណោះទេ ប៉ុន្តែគោលការណ៍នេះពាក់ព័ន្ធទៅនឹងបទប្បញ្ញត្តិនៃច្បាប់នេះទាំងមូល។